**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តសៀមរាប**

**រដ្ឋបាលក្រុងសៀមរាប**

លេខ:......✓............

ថ្ងៃអង្គារ ១៣រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ក្រុងសៀមរាប ថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤

**សូមគោរពជូន**

**ប្រធានគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រជាពលរដ្ឋក្រុងសៀមរាប**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីលទ្ធផលនៃការដាក់ពាក្យ និងការទទួលពាក្យស្នើសុំឈរឈ្មោះជាប្រធានការិយាល័យប្រជាពលរដ្ឋ។

**យោង ៖** សេចក្តីជូនដំណឹងចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ ក្រុងសៀមរាប។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរពជម្រាបជូន លោកប្រធានគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុងសៀមរាប មេត្តាជ្រាបថា ៖ គណៈកម្មាធិការបោះឆ្នោតបានប្រកាសផ្សព្វផ្សាយ និងទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនសម្រាប់មុខតំណែងប្រធានការិយាល័យប្រជាពលរដ្ឋក្រុងសៀមរាប ចាប់តាំងពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង០៥:០០រសៀល។

ក្រោយពីថ្ងៃផុតកំណត់ទទួលពាក្យខាងលើនេះ ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រុងសៀមរាប បានទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនសម្រាប់មុខតំណែងប្រធានការិយាល័យប្រជាពលរដ្ឋចំនួន០៩រូប។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានគណៈកម្មាធិការបោះឆ្នោត មេត្តាជ្រាបជារបាយការណ៍។

សូមលោកប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

សូមជូនភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះបេក្ខជនដែលបានដាក់ពាក្យស្នើសុំចំនួន ១ច្បាប់។

**ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**

**អ៊ីង សាវ៉ាន់**

រដ្ឋបាលក្រុងសៀមរាប ភូមិកសិកម្ម សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប Siem Reap Municipality, Kaksikam Village, Sangkat Srangae, Siem Reap Municigalty, Siem Reap Provice, E-mail: siemreap1710@gmail.com Tel:(855) 63 966 636